ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៨...០១៥...០០៧ ប្រ.ក

# ប្រកាស
## ស្តីពី
## លក្ខណៈសម្គាល់នៃធនប័ត្រ ប្រភេទ ១០០ រៀល គំរូថ្មី

***********

អនុលោមតាមអនុក្រឹត្យលេខ ០៤ អនក្រ.បក របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៥ ស្តីពីការចេញផ្សាយធនប័ត្រប្រភេទ ១០០ រៀល គំរូថ្មីក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារជាតិនៃកម្ពុជាសូមប្រកាសផ្សាយជាសាធារណៈ នូវលក្ខណៈសំគាល់នៃធនប័ត្រគំរូថ្មីនេះ មានដូចខាងក្រោម ៖

**ក- លក្ខណៈទូទៅ ៖**

- ទំហំធនប័ត្រ ៖ បណ្តោយ ១៣៨ មម និងទទឹង ៦៤ មម
- ពណ៌ចម្បង គឺពណ៌ស្លាទុំ និងពណ៌ត្នោត ។

**ខ- ផ្ទៃខាងមុខ ៖**

- **ផ្នែកកណ្តាល** ខាងស្តាំត្រូវបានរំលេចឡើងនូវព្រះឆាយាល័ក្ខណ៍មើលចំពីមុខ នៃ **ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ** កាលពីព្រះអង្គកំពុងសាងព្រះផ្នួស ខាងឆ្វេងមានលេខ " ១០០ " នៅពីលើគេ បន្ទាប់មកគឺជាហត្ថលេខារបស់ទេសាភិបាលនិងអគ្គបេឡា ព្រមទាំងរូបព្រះអង្គផ្កាញ់មា និងនៅពីក្រោមមានលេខ-មាលាបោះពុម្ពដោយទឹកខ្មៅពណ៌ខ្មៅ រូបចម្លាក់នាគក្បាល ៥ ពាំផ្កា និងអក្សរ " មួយរយរៀល " ព្រមទាំងអក្សរ " អ្នកក្លែងក្រដាសប្រាក់នឹងត្រូវផ្តន្ទាទោសតាមច្បាប់ " នៅគែមខាងក្រោមនោះ ។

- **ផ្នែកខាងស្តាំ** ជ្រុងលើមានអក្សរ "ធនាគារជាតិនៃកម្ពុជា" និងជ្រុងក្រោមមានលេខ " ១០០ " ព្រមជាមួយលេខ " 100 " នៅពីក្រោមនោះ ។

- **ផ្នែកខាងឆ្វេង** មានលេខ "100" ព្រាលៗបោះពុម្ពតាមបន្ទាត់បញ្ឈរ ព្រមទាំងរូបភាពក្បាច់លំអពណ៌ប្រាក់ក្លាយពីក្បាច់អង្គរក្នុងទម្រង់ពងត្រីបំបែក បោះពុម្ពកាត់ទទឹងក្រដាសប្រាក់ពីលើដល់ក្រោម និងជ្រុងក្រោមមានគំនូសបន្ទាត់ខ្លីៗជាច្រើនបង្កើតឡើងដោយលេខ" ១០០ " ដ៏តូចល្អិត ។

**គ- ផ្ទៃខាងខ្នង ៖**

- **ផ្នែកកណ្តាល** រូបភាពត្រូវបានរំលេចឡើងគឺជាព្រះវិហារព្រះកែវមរកត និងមានអក្សរ " មួយរយរៀល " នៅពីក្រោមនោះ ។

ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**- ផ្នែកខាងស្តាំ** ជ្រុងលើមានលេខ " 100 " បោះពុម្ពតាមបន្ទាត់បញ្ឈរ ចំកណ្តាលជារូបបដិមាព្រះកែវមរកត និងនៅជ្រុងក្រោមមានលេខ " ១០០ " ។

**- ផ្នែកខាងឆ្វេង** ជ្រុងលើមានអក្សរ "ធនាគារជាតិនៃកម្ពុជា" អក្សរ " NATIONAL BANK OF CAMBODIA " និងលេខ " 2014 " នៅកណ្តាលមានរូបភាពព្រាលៗជារូបទេពប្រណម្យ ព្រមទាំងក្បាច់លំអពណ៌ប្រាក់ផ្តុំឡើងដោយលេខ " ១០០" បញ្ច្រាស់គ្នា និងនៅជ្រុងក្រោមមានលេខ " ១០០" ។

ចាប់ពីថ្ងៃចេញប្រកាសនេះតទៅ ធនប័ត្រប្រភេទ ១០០ រៀល គំរូថ្មី ត្រូវបានដាក់ឲ្យចរាចរ ទន្ទឹមគ្នាជាមួយនឹងធនប័ត្រជាតិប្រភេទផ្សេងៗទៀតដែលត្រូវបានចេញផ្សាយរួចមកហើយ ។ សាធារណជនគ្រប់រូបត្រូវពិនិត្យ-សម្គាល់ធនប័ត្រថ្មីនេះឲ្យបានច្បាស់លាស់ ដើម្បីជៀសវាងការភ័ន្តច្រឡំ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៥

**ទេសាភិបាល**

**ជា ចាន់តូ**